01365300

002/19-09-2007-ECCC/TC
E1/484

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 12 / 2016
ម៉ោង (Time/Heure): 11:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ
## ថ្ងៃ ចន្ទ ទី ១៧ ខែ តុលា ឆ្នាំ ២០១៦
## សវនាការលើភ័ស្តុតាង - ថ្ងៃ ៤៦៥

រៀបចំដោយ៖ លោកស្រី សែ គុលវុឌ្ឍី និង កញ្ញា Evelyn CAMPOS SANCHEZ

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ |
| ចៅក្រមបំរុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ គុលវុឌ្ឍី, កញ្ញា Evelyn CAMPOS SANCHEZ |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត, លោក Nicholas KOUMJIAN, លោក JOSEPH ANDREW BOYLE |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក វ៉ែន |

| |
|---|
| ពៅ, លោក ឡោ ជុនធី |
| ដើមបណ្ដឹង/សាក្សី/អ្នកជំនាញ៖ សាក្សី លោក ជាល ជឿន (2-TCW-960), សាក្សី 2-TCW-1037 (សាក្សីប្រភេទ "ក"), លោក មឿន សុវណ្ណ (មេធាវីប្រឹក្សាសាក្សី 2-TCW-1037) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ិច អរុណ, លោកស្រី សួរ សុទ្ធារី |
| ផ្សេងៗ៖ កញ្ញា ស្រី ណាក់, លោកស្រី ពេជ ចរិយា, លោក មៀច សុវណ្ណា, លោក នូ មនោរ័ត្ន, កញ្ញា Aureliarita MARCELLUS |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.១២ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១០ | បញ្ចប់ម៉ោង៖ ១០.៣២ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.២៤ | បញ្ចប់ម៉ោង៖ ១៣.៣១ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤៤ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ១៧ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៦ | ០៩.០៧ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៩ | ០៩.១០ |
| ការបន្តតាំងសំណួរទៅសាក្សី ជាល ជឿន (2-TCW-960) | សហព្រះរាជអាជ្ញា<br>មេធាវីការពារក្ដី នួន ជា | ០៩.១១<br>១០.៣៧ | ១០.១១<br>១១.២២ |
| សេចក្ដីសម្រេចធ្វើសវនាការជាអសាធារណៈទាក់ទងនឹងឯកសារដែលពាក់ព័ន្ធនឹងសាក្សី 2-TCW-1066 | អង្គជំនុំជម្រះ | ១១.១៧ | ១១.១៨ |
| ការតាំងសំណួរទៅសាក្សី 2-TCW-1037 | អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួន ជា | ១៣.៣៧<br>១៣.៤៥<br>១៥.១៥ | ១៣.៤៤<br>១៤.៤៤<br>១៥.៥៧ |

| | | | |
|---|---|---|---|
| | សហព្រះរាជអាជ្ញា | ១៥.៥៧ | ១៦.១០ |
| សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី នួនជា សុំឱ្យទទួលយកឯកសារចំនួន ០៨ និងបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឯកសារចំនួន ២ (E445/1) | អង្គជំនុំជម្រះ | ១៣.៣១ | ១៣.៣៦ |
| សារណាផ្ទាល់មាត់ទាក់ទងនឹងកំណត់ហេតុរបស់អ្នកជំនាញ 2-TCE-98 ដែលមានឯកសារ E3/7338 | សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ<br>មេធាវីនាំមុខ<br>មេធាវីការពារក្តី នួន ជា | ១៥.០៥<br>១៥.០៩<br>១៥.១០<br>១៥.១១ | ១៥.១០<br>១៥.០៩<br>១៥.១០<br>១៥.១១ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការបន្តតាំងសំណួរទៅសាក្សី ជាល ជឿន (2-TCW-960)**

សហព្រះរាជអាជ្ញា និង មេធាវីការពារក្តី នួន ជា បានបន្តតាំងសំណួរទៅកាន់សាក្សី ជាល ជឿន (2-TCW-960)។

**សេចក្តីសម្រេចធ្វើសវនាការជាអសាធារណៈទាក់ទងនឹងឯកសារដែលពាក់ព័ន្ធនឹងសាក្សី 2-TCW-1066**

អង្គជំនុំជម្រះបានបង្គាប់ឱ្យធ្វើសវនាការជាអសាធារណៈ ដើម្បីអនុញ្ញាតិឱ្យមេធាវីការពារក្តី នួន ជា អាចសួរដេញដោលទៅសាក្សី ជាល ជឿន ដោយប្រើប្រាស់សម្រង់ពីឯកសារ E3/10685 និង E3/10683 ដែលពាក់ព័ន្ធនឹងសាក្សី 2-TCW-1066 ជាសាក្សីដែលទទួលបានវិធានការការពារ។

**សេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំ របស់មេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកឯកសារចំនួន ៨ និងបំពេញកិច្ចស៊ើបសួរទាក់ទងនឹងឯកសារចំនួន ២ (E445/1)**

អង្គជំនុំជម្រះយោងទៅលើសំណើរបស់មេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន ៨៧(៤) និងវិធាន ៩៣ នៃវិធានផ្ទៃក្នុង (ឯកសារ E445/1) ដែលបានដាក់ជាឯកសារសម្ងាត់នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ សុំឱ្យទទួលយកឯកសារចំនួន ៨ និងឱ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឯកសារចំនួនពីរ។ សវនាការស្តាប់សេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ឆ្លើយតបទៅនឹងសំណើនេះ បានធ្វើឡើងនៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦។ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះទទួលយកឯកសារទី ១ ដល់ឯកសារទី ៧ និងបដិសេធមិនទទួលយកឯកសារទី ៨។ ដោយហេតុថាអង្គជំនុំជម្រះបដិសេធមិនទទួលយកឯកសារទី ៨ ហេតុដូច្នេះហើយ សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកឯកសារចំនួន ៣ ផ្សេងទៀត លែងមានភាពចាំបាច់ទៀតហើយ។ ទាក់ទិននឹងឯកសារទី ១ អង្គជំនុំជម្រះបង្គាប់ឱ្យមេធាវីការពារក្តី នួន ជា បង្ហាញនូវផ្នែកទាំងឡាយនៃឯកសារដែលមានចំនួន ២១៥ ទំព័រ ដែលពាក់ព័ន្ធបំផុតទៅនឹងសក្ខីកម្មរបស់អ្នកជំនាញ 2-TCE-98 ដែលពួកគាត់មានបំណងយកមកប្រើប្រាស់។ ចំពោះសំណើសុំ អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានស្នើឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញទាក់ទងអ្នកជំនាញដើម្បីស្នើសុំឱ្យគាត់ផ្តល់នូវសំណៅពេញលេញនៃឯកសារទី១។
អង្គជំនុំជម្រះ បដិសេធសំណើសុំ អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ទាក់ទិននឹងឯកសារទី២។
សំអាងហេតុជាលាយលក្ខណ៍អក្សរពេញលេញសម្រាប់សេចក្តីសម្រេចនេះនឹងចេញក្នុងពេលសមស្រប ខាងមុខ។

<u>ការតាំងសំណួរទៅសាក្សី 2-TCW-1037</u>

ប្រធានអង្គជំនុំជម្រះ បានតាំងសំណួរបឋម និង ប្រាប់ពីសិទ្ធិ និងករណីយកិច្ចសំខាន់ៗទៅកាន់សាក្សី 2-TCW-1037។ បន្ទាប់មក មេធាវីការពារក្តី នួន ជា និង សហព្រះរាជអាជ្ញា បន្តតាំងសំណួរទៅកាន់សាក្សី 2-TCW-1037។

<u>សារណាផ្ទាល់មាត់ទៅលើកំណត់ដៃរបស់អ្នកជំនាញ 2-TCE-98 ទាក់ទងនឹងឯកសារ E3/7338</u>

អង្គជំនុំជម្រះបានស្នើឱ្យភាគីធ្វើការឆ្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងកំណត់ដៃនៃកិច្ចសម្ភាសន៍របស់អ្នកជំនាញ 2-TCE-98 ជាមួយសម្តេច នរោត្តម សីហនុ និង អៀង សារី នៅក្នុងឆ្នាំ ១៩៨៣ និង ១៩៨៥ ដើម្បីប្រើប្រាស់នៅក្នុងការតាំងសំណួរទៅអ្នកជំនាញ។

Newly Admitted Documents

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/10699 | | 01335024-01335238 | Stephen J. Morris, 'The Origins of the Soviet-Vietnamese Alliance', Doctoral Dissertation, Columbia University, 1987 | P | / | / | / |
| E3/10700 | | 01335239-01335280 | Morris J., Stephen (1999). The Soviet Chinese-Vietnamese Triangle in the 1970s: The View From Moscow. | P | / | / | / |
| E3/10701 | | 01335281-01335284 | Attachment 3: Stephen J. Morris "The War We could Have Won," New York Times, 1 May 2005 | P | / | / | / |
| E3/10702 | | 01335285-01335286 | Attachment 4: Thomas Lippman 'A Researcher's dream Find on U.S POWs Turns into a Nightmare'/ Washington Post 25Aprl 1993, A04 | P | / | / | / |
| E3/10703 | | 01335287-01335289 | [Attachment 5] Chandler, David (2000). Book review of Stephen J. Morris's Why Vietnam Invaded Cambodia: Political culture and the Causes of War. | P | / | / | / |
| E3/10704 | | 01335290-01335291 | [Attachment 6] Stephen J. Morris "letter to the editor : Khmer Rouge crimes and Moral Absurdities," Wall Street Journal , 15 June 1995,A15 | P | / | / | / |
| E3/10705 | | 01335292-01335293 | [Attachment 7] Disowning Morris', Phnom Penh Post, 30 June 1995 | P | / | / | / |

## Reclassified Documents

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/3481 | | P 00440815-00440815 P 00440815-00440815 P 00440815-00440815 | Photograph depicting KOY Thoun and VORN Vet | P | P 00440815-00440815 | P 00440815-00440815 | P 00440815-00440815 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1358 | | 00679851-00679854 00168258-00168306 00662237-00662240 | Annex 00033: Foreign Broadcast Information Service collection of reports for August 1977 | P | / | 00168287 | / |
| E3/10698 | | P 01337595-01337595 P 01337595-01337595 P 01337595-01337595 | Toat Thoeun picture | P | / | / | / |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1170 | | 00443012-00443062 00602543-00602593 00544894-00544942 | DC-Cam Khmer Rouge Black Journal | P | 00443016-17 | 00602544 | 00544895 |
| E3/2285 | D108/26.86 | 00009067-00009317 00873122-00873671 | [Surrogate Sheet] Annex 86: List of Prisoners | P | / | / | / |
| E3/1068R | | TR01208995-TR01208995 | CD Recording of Interview of witness CHEAL Choeun | C | / | (Answer 42) 1hr 12 Min<br><br>(Answer 121) 2h 12 Mon 20 Sec | / |
| E3/10681 | | 01201719-01201759 01213331-01213358 | Written Record of Interview witness CHEAL Choeun ជាល ជឿន | C | 01201738 01201727 | 01213345 01213337 | / |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/9580 | | 00951900-00951912 00978415-00978429 01004430-01004443 | Written Record of Interview of 2-TCW-1037 [REDACTED] | C | 00951901 00951902 | 00978412 00978425 00978422 | 01004440 01004437 |
| E29/489/1 | | 01331002-01331003 01331001-01331001 | Response of Rob Lempkin to Trial Chamber Inquiry | C | 01331002-03 | 01331001 | / |
| E3/10666 | | 01326300-01326358<br><br>01330495-01330584 | Transcript of interview of 2-TCW-1037 | C | 01326301 01326314 01326340 01326309 01326355 01326319 | 01330496 01330517 01330570 01330510 01330580 01330525-26 | / |
| E3/10683 | | 01068121-01068153 01106425-01106448 | Written Record of Interview of 2-TCW-1066 [REDACTED] | C | / | / | / |
| E3/4202 | | 00858214-00858410 00920122-00920144 00757471-00757568 00849349-00849484 | Annex 2: Book by GINA Chon and THET Sambath entitled “Behind the killing fields: a Khmer Rouge leader and one of his victims” | P | 00858342 | 00757532 | 00849437 |
| E3/7338 | | 01001657-01001985 | Attachment 4: Stephen J Morris Why Vietnam Invaded Cambodia Political Culture and the Causes of War | P | / | 01001662 | / |
| E3/10683 | E319/52.3.3 | 01068121-01068153 01106425-01106448 | [REDACTED] Written Record of Interview of 2-TCW-1066 [REDACTED] | C | / | / | / |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់

ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៨)

- បង្គាប់ឱ្យប្រើប្រាស់សម្រង់ឯកសារពីឯកសារ E3/10685 និង E3/10683 នៅក្នុងសវនាការជាអសារធារណៈ។ (១០.៣៣)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹកនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ ។ (១៦.១២)

| <u>កាលវេលាសវនាការបន្ត</u> |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ... ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

លោកស្រី សែ គុនធា Evelyn CAMPOS SANCHEZ